**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែសីហា ឆ្នាំ២០១៦

នៅក្នុងខែសីហា ឆ្នាំ២០១៦ នេះព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន:

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន០១លើក

-អញ្ជើញទទួលព្រះរាជដំណើររបស់**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា យាងនិវត្តន៍មកដល់មាតុប្រទេស បន្ទាប់ពីបានយាងពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន

-អនុញ្ញាតឲ្យឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ចំនួន០៥រូប ចូលជួបសម្តែងការគួរសម និងជម្រាបលា ព្រមទាំងសុំអនុសាសន៍ណែនាំមុននឹងចេញទៅបំពេញបេសកកម្មតាមបណ្តាប្រទេសជាមិត្ត

-អនុញ្ញាតឲ្យឯកឧត្តម Jan Yun Gon ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Dato'Sri Hasan Malek ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម U Mynit Soe ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum sarith@camnet.com.kh

គួរសម និងសរនោការ

-អនុញ្ញាតឲ្យក្រុមសិល្បករខ្មែរកាន់ឧបករណ៍ភ្លេងពិណពាទ្យ មកពីសាលាវិចិត្រសិល្បៈរាជធានីភ្នំពេញ និងសិល្បករជនជាតិដើមភាគតិច មានឧបករណ៍ ម៉ឹម និងចាប៉ី មកពីខេត្តរតនគិរី ចូលជួបសម្តែងការគួរសម

-អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខជាមួយមន្ត្រីរាជការ មន្ត្រីចូលនិវត្តន៍ ចៅសង្កាត់ មន្ត្រីភូមិ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ កុមារកំព្រា សិល្បករ កម្មករ កម្មការិនី ក្រុមអ្នកបច្ចេកទេសចិន ដូនជី តាជី គណៈកម្មការវត្ត ប្រជាពលរដ្ឋ ចាស់ជរា និងអ្នករបួសពិការ ចំនួន១៨លើក នៅរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺ

-អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសព **លោក សាន ចាន់ណាក់** អនុប្រធាននាយកដ្ឋានកិច្ចការនារី និងយេនឌ័រ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តស្រះចក សង្កាត់ស្រះចក រាជធានីភ្នំពេញ

-បានទទួលព្រះរាជសារព្រះរាជប្រទានសិទ្ធិចំនួន៤៣ និងធ្វើសំណើក្នុងនាមសម្តេចប្រមុខរដ្ឋស្តីទី ចំនួន០១

-បានទទួលសំណើពីក្រុមប្រឹក្សាធម្មនុញ្ញចំនួន០៩ រដ្ឋសភាចំនួន០១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន០១ ពីរាជរដ្ឋាភិបាលចំនួន៣៩ និងជ្រាបជាព័ត៌មានចំនួន១០២ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើព្រះរាជក្រមចំនួន០៣ ព្រះរាជក្រឹត្យចំនួន៤០ និងជ្រាបជាព័ត៌មាន ចំនួន១៥៩ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញចូលរួមក្នុងពិធីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខេត្ត និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅខេត្តកំពត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៧ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន១១២ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍សមាគមមិត្តភាពកម្ពុជា-ចិន ស្តីពីការរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារទីស្នាក់ការសមាគមមិត្តភាពកម្ពុជា-ចិន នៅសាលប្រជុំពិសេសព្រឹទ្ធសភា

-អញ្ជើញផ្តល់បទសម្ភាសន៍ ជាមួយយុវជនសហភាពសហព័ន្ធយុវជនកម្ពុជា ខេត្តព្រៃវែង នៅសាលពិសេស២ ព្រឹទ្ធសភា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ អគារសមាគមមិត្តភាពកម្ពុជា-ចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៅវិមានព្រឹទ្ធសភា

-អញ្ជើញនាំយកទៀនព្រះវស្សា ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាចំនួន០៣វត្ត ស្ថិតនៅឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាទៅគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម S R Nathan អតីតប្រធានាធិបតីទី៦ នៃសាធារណរដ្ឋសិង្ហបុរី នៅស្ថានទូតសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩០ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន៩៩ច្បាប់ ។

**២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែសីហានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**២.១ មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន នៅមណ្ឌលភូមិភាគទី៧ ក្នុងខេត្តកំពង់ឆ្នាំង

-អញ្ជើញជួបសវនាការជាមួយក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្វែងយល់អំពីការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងនិយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាព បច្ចេកទេស និងវិជ្ជាជីវៈ ឲ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ និងការការពារពលករខ្មែរ ដែលត្រូវបញ្ជូនទៅធ្វើការនៅបរទេស ។

**២.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ផ្ញើជូនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី ព្រមទាំងទទួលពាក្យបណ្តឹងជូនជ្រាប១៤ករណី ។

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ និងតំណាងក្រុមប្រជាពលរដ្ឋ ដែលរស់នៅតាមបណ្តាសង្កាត់មួយចំនួន ក្នុងរាជធានីភ្នំពេញ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បើកកិច្ចប្រជុំពិភាក្សាការងាររៀបចំវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បើកកិច្ចប្រជុំពិនិត្យ និងឆ្លងរបាយការណ៍កិច្ចពិភាក្សារវាងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ និងថ្នាក់ដឹកនាំខេត្តកណ្តាល ពិនិត្យរបៀបវារៈកម្មវិធីវេទិកាបូកសរុបថ្នាក់ភូមិភាគ និងពិនិត្យតម្រូវការកសាងសមិទ្ធផលរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បើកកិច្ចប្រជុំ ស្តីពីកិច្ចពិភាក្សាគម្រោងចុះបេសកកម្មសិក្សាឈ្វេងយល់ថ្នាក់ឃុំ នៅស្រុកចំនួនបី នៅខេត្តព្រៃវែង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បើកកិច្ចប្រជុំអំពីបច្ចុប្បន្នភាពស្តីពីស្ថិតិទិន្នន័យគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់

-អញ្ជើញដឹកនាំប្រជុំក្រុមការងារ ជាមួយមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលនៃក្រុមសភាជាតិកម្ពុជានៃសភានិយាយភាសាបារាំង APF ដើម្បីពិនិត្យពិភាក្សាអំពីគម្រោងរៀបចំសិក្ខាសាលារបស់ APF ក្រោមប្រធានបទ "ច្បាប់ហិរញ្ញវត្ថុ"

-អញ្ជើញចូលរួមប្រជុំការងាររវាងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង ដើម្បីត្រៀមទទួលដំណើរទស្សនកិច្ចរបស់ ឯកឧត្តម Vincent Eblé សមាជិកព្រឹទ្ធសភា និងជាប្រធានក្រុមមិត្តភាពបារាំង-កម្ពុជា

-អញ្ជើញចូលរួមកិច្ចប្រជុំជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការពិនិត្យពិភាក្សាអំពីគម្រោងថវិកា និងថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៧របស់ព្រឹទ្ធសភា

-អញ្ជើញប្រជុំពិភាក្សាការងារជាមួយលោក **យូរ ហ្កែនឡេមប៊ើក** (Mr. Juergen LEHMBERG) ប្រធានផ្នែកអភិបាលកិច្ចល្អនៃកម្មវិធីអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចតំបន់ (REDIII) នៃអង្គការ GIZ របស់ប្រទេសអាល្លឺម៉ង់ និងសហការី

-អញ្ជើញជួបពិភាក្សាការងារជាមួយលោក **ហាខាន់ អាតាស៊ើវ** (Hakan Atasever) នាយកវិទ្យាស្ថានមេគង្គកម្ពុជាMDI អំពីគម្រោងជីកអណ្តូងទឹកស្អាតជូនប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមប្រជុំការងាររវាង ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-បារាំង ស្តីពី "ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី"

-អញ្ជើញចូលរួមប្រជុំការងារ ស្តីពី "ក្រមសីលធម៌សមាជិកព្រឹទ្ធសភា"

-អញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ និងមហាសន្និបាតលើកទី៩ នៃសភាតំបន់អាស៊ី (APA)

-អញ្ជើញចូលរួមកិច្ចប្រជុំក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា ជាមួយសភាសហព័ន្ធមីយ៉ាន់ម៉ា ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការចាត់តាំងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា ជាមួយសភាសហព័ន្ធមីយ៉ាន់ម៉ា

-អញ្ជើញចូលរួមប្រជុំពិភាក្សាពិនិត្យខ្លឹមសារ នៃសេចក្តីព្រាងសេចក្តីសម្រេចទាំង ១៩ ដែលទទួលបានពីអគ្គលេខាធិការដ្ឋាន APA ប្រចាំទីក្រុងតេអេរ៉ង់

-ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-ថៃ ប្រជុំផ្សព្វផ្សាយសេចក្ដីសម្រេចចាត់តាំងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-ថៃ និងពិនិត្យពិភាក្សាផ្ដល់យោបល់លើផែនការប្រតិបត្តិប្រចាំឆមាសទី២ ឆ្នាំ២០១៦ និងពិភាក្សាការងារជាមួយឯកអគ្គរាជទូតថៃឡង់ដ៍ប្រចាំព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមសិក្ខាសាលាក្រោមប្រធានបទផ្ដោតសំខាន់លើវិស័យបង្រៀនអក្ខរកម្មជាភាសាអង់គ្លេស និងសកម្មភាពឲ្យមានការងារមនុស្សធម៌នៅតាមបណ្ដាខេត្តនានា នៅសណ្ឋាគារ សាន់វេ (SUN WAY)

-អញ្ជើញធ្វើបទបង្ហាញស្ដីពី តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ដល់លោកគ្រូ អ្នកគ្រូ និងសិស្សនិស្សិតចំនួន១៨៥នាក់ ដែលមកពីវិទ្យាស្ថានអន្តរជាតិកម្ពុជា-អាស៊ាន

-អញ្ជើញសម្ពោធអណ្ដូងទឹកចំនួន០៤ និងស្រះទឹកចំនួន០១ (០២អណ្ដូង នៅឃុំចុងជាច និងឃុំគោកស្រុក ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ០២អណ្ដូង នៅឃុំវាល និងឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងស្រះទឹកចំនួន០១ ទំហំ៥៩ម×៣៩ម ជម្រៅ២ម នៅឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង) ជូនប្រជាពលរដ្ឋប្រើប្រាស់ជាប្រយោជន៍សាធារណៈ

-អញ្ជើញចូលរួមវេទិកាពិគ្រោះយោបល់ ពង្រាងច្បាប់សិទ្ធិទទួលបានព័ត៌មានជាមួយក្រុមស្ត្រី

-អញ្ជើញជួបពិភាក្សាជាមួយតំណាងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព(PDP) ដើម្បីត្រៀមរៀបចំសិក្ខាសាលាស្ដីពី គោលនយោបាយគ្រឿងស្រវឹង

-អញ្ជើញចូលរួមសិក្ខាសាលា ដែលរៀបចំឡើងដោយមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ នៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមវេទិកាស្ដីពី "ការការពារ និងអភិរក្សធនធានធម្មជាតិ"

-អនុញ្ញាតឲ្យឯកឧត្តម **ឃឹម អ៊ី** ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់អមរដ្ឋសភា ជួបពិភាក្សាការងារ

-អញ្ជើញចូលរួមបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលជូនដល់ព្រះសពព្រះនាម **កែន ឌុល** អតីតព្រះចៅអធិការវត្តត្រពាំងឫស្សី ហៅអង្កែង ស្ថិតនៅក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមរំលែកទុក្ខគ្រួសារសព លោក ហេង គឹមហៃ ប្រធានលេខាធិការដ្ឋានគណៈកម្មការទី៩ ។

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះបេសកកម្មទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន២២០លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព និវត្តន៍ជន លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗសរុប ចំនួន៧៦លើក ។

**៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** អញ្ជើញទស្សនកិច្ចសិក្សារោងចក្រកែច្នៃស្វាយ នៅសាធារណរដ្ឋកូរ៉េខាងត្បូង

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់សភាតំបន់អាស៊ី (APA) នៅទីក្រុងអ៊ីស្លាមម៉ាបាដ នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

-ឯកឧត្តម **ឈិត គឹមយាត** និងឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ាលើកទី៨ (The 8th AIPA Caucus) នៅទីក្រុងលួងព្រះបាង្គ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពី "ការធ្វើចំណាកស្រុកក្នុងប្រទេសអាស៊ាន" និង"ការអភិរក្សសត្វព្រៃ និងធនធានធម្មជាតិ" នៅទីក្រុងលួងព្រះបាង្គ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ឯកឧត្តម **យូ ស៊ាងហេង** អញ្ជើញចុះជួបសំណេះសំណាលជាមួយពលករខ្មែរ (ពលករតាមផ្សារ និងធ្វើការជាអ្នកនេសាទសមុទ្រ) នៅព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីឲ្យពួកគាត់មកចុះឈ្មោះបោះឆ្នោតថ្មីនៅព្រះរាជាណាចក្រកម្ពុជាវិញ

-អនុញ្ញាតឲ្យទីប្រឹក្សាអមស្ថានទូតសហភាពសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបសំណេះសំណាល និងពិភាក្សាការងារ

-អនុញ្ញាតឲ្យឯកឧត្តម **វ៉ី ផុកថាញ់** អភិបាលខេត្តយ៉ាឡាយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ស្ថិតនៅក្រុងបានលុង ខេត្តរតនគិរី ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ខែកញ្ញា ឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ